REPUBLIK INDONESIA

# ពិធីសារ

ក្នុងពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានឯកភាពថា បញ្ញត្តិខាងក្រោមត្រូវក្លាយជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ÷

១. សម្រាប់គោលដៅនៃវាក្យខណ្ឌ (ជ) កថាខណ្ឌ២ ក្នុងមាត្រា៥ គ្រឹះស្ថានអចិន្ត្រៃយ៍កើតមានឡើងចាប់ពីកាលបរិច្ឆេទ ដែលគ្រឿងចក្រសម្រាប់ខួងអណ្តូងប្រេងកាត ឬនាវាសម្រាប់ផ្គត់ផ្គង់ មានវត្តមាននៅក្នុងដែនដីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងណាមួយ។

២. សម្រាប់គោលដៅនៃមាត្រា៧ ពុំមានករណីណាមួយនៃមាត្រានេះ ត្រូវមានផលប៉ះពាល់ដល់ការអនុវត្តច្បាប់ណាមួយនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទាក់ទិននឹងការកំណត់ពន្ធលើប្រាក់ចំណូលពីការលក់ធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងអនិវាសជនដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះឡើយ លើកលែងតែការធានារ៉ាប់រងបន្ត។

៣. សម្រាប់គោលដៅនៃកថាខណ្ឌ៥ ក្នុងមាត្រា១០ការកំណត់អត្រាពន្ធនេះ មិនត្រូវមានផលប៉ះពាល់ដល់បញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យាបែងចែកផលិតផលណាមួយ ដែលទាក់ទិននឹងវិស័យប្រេង និងឧស្ម័ន ព្រមទាំងកិច្ចសន្យានៃការងារនានា ក្នុងវិស័យធនធានរ៉ែ ដែលបានបញ្ចប់រវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬក្រុមហ៊ុនប្រេងនិងឧស្ម័នរដ្ឋដែលពាក់ព័ន្ធ ឬស្ថាប័នណាមួយនៃរដ្ឋនោះ ជាមួយបុគ្គលដែលជានិវាសនជន នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ដើម្បីជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់នៅរដ្ឋធានីហ្សាការតា ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ និងនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ ជាភាសាឥណ្ឌូនេស៊ី ភាសាខ្មែរ និងភាសាអង់គ្លេស។ អត្ថបទទាំងអស់មានតម្លៃជាផ្លូវការស្មើគ្នា វៀរលែងតែក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

| | |
|---|---|
| **តំណាងរដ្ឋាភិបាលនៃ** | **តំណាងរាជរដ្ឋាភិបាលនៃ** |
| **សាធារណរដ្ឋឥណ្ឌូនេស៊ី** | **ព្រះរាជាណាចក្រកម្ពុជា** |
| **បណ្ឌិត ស្រី មូលីយ៉ានី ឥន្រ្ទាវ៉ាទី** | **បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** |
| **រដ្ឋមន្រ្តីក្រសួងហិរញ្ញវត្ថុ** | **ឧបនាយករដ្ឋមន្ត្រី** |
| | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |